ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ០៤ អយក.សណន

# សេចក្តីណែនាំ
# ស្តីពី
# ការគ្រប់គ្រងគុណភាព នៃការបណ្តុះបណ្តាលថ្នាក់បណ្ឌិត នៅតាមគ្រឹះស្ថានឧត្តមសិក្សាក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា

យោង៖
- អនុក្រឹត្យលេខ១៥១ អនក្រ.បក ស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០
- អនុក្រឹត្យលេខ ១៥៣ អនក្រ.បក ស្តីពីក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤
- ប្រកាសលេខ ២៩១៤ អយក.ប្រក ស្តីពីលក្ខខណ្ឌនិងលក្ខណវិនិច្ឆ័យលម្អិតសម្រាប់ដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១២
- របាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំស្តីពី ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣

ក្រសួងអប់រំ យុវជន និងកីឡា បានសង្កេតឃើញថា ចំនួននិស្សិតកំពុងសិក្សា និងបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតមានការកើនឡើងជាបន្តបន្ទាប់។ ក្នុងន័យនេះ ដើម្បីលើកកម្ពស់ និងធានាគុណភាពនៃការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជន ក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា នូវកិច្ចការសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

## 1. ការជ្រើសរើសនិស្សិតចូលរៀន

- គ្រឹះស្ថានឧត្តមសិក្សាត្រូវពិនិត្យ និងកំណត់ឡើងវិញនូវលក្ខខណ្ឌ នៃការជ្រើសរើសនិស្សិតចូលរៀនថ្នាក់បណ្ឌិតឱ្យបានលម្អិត និងច្បាស់លាស់ និងត្រូវផ្សព្វផ្សាយជាសាធារណៈ។
- គ្រឹះស្ថានឧត្តមសិក្សាត្រូវពង្រឹងយន្តការនៃការពិនិត្យលើសំណុំពាក្យសុំចូលរៀន និងការប្រឡងជ្រើសរើសនិស្សិតចូលរៀនឱ្យបានត្រឹមត្រូវតាមការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា

ដោយរៀបចំឱ្យមានការប្រឡងលើមុខវិជ្ជាឯកទេស និង/ឬ មុខវិជ្ជាតម្រូវ និងការការពារសំណើគម្រោងស្រាវជ្រាវ។

2. **កម្មវិធីសិក្សា**

- គ្រឹះស្ថានឧត្តមសិក្សាត្រូវរៀបចំកម្មវិធីសិក្សាតាមទម្រង់ខាងក្រោម៖
  - កម្មវិធីសិក្សាបែបការរៀនមុខវិជ្ជា និងការសរសេរនិក្ខេបបទ
  - កម្មវិធីសិក្សាបែបការស្រាវជ្រាវ និងការសរសេរនិក្ខេបបទ
- គ្រឹះស្ថានឧត្តមសិក្សាត្រូវរៀបចំកម្មវិធីសិក្សាលម្អិតស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា និងត្រូវសុំការទទួលស្គាល់កម្មវិធីសិក្សានេះ ពីក្រសួងអប់រំ យុវជន និងកីឡា មុននឹងបណ្តុះបណ្តាល។

3. **ប្រធានបទសិក្សាស្រាវជ្រាវថ្នាក់បណ្ឌិត**

- គ្រឹះស្ថានឧត្តមសិក្សាត្រូវសម្របសម្រួលការជ្រើសរើសប្រធានបទសិក្សាស្រាវជ្រាវរបស់និស្សិត ដែលត្រូវជាប្រធានបទថ្មី និងចូលរួមដោះស្រាយបញ្ហាជាក់ស្តែងនៅក្នុងសហគមន៍ ឬក្នុងឧស្សាហកម្ម និងត្រូវស្របតាមវិស័យអាទិភាពរបស់ប្រទេស ឬពិភពលោក
- គ្រឹះស្ថានឧត្តមសិក្សាត្រូវមានគណៈកម្មការត្រួតពិនិត្យ និងសម្រេចលើប្រធានបទសិក្សាស្រាវជ្រាវរបស់និស្សិត។ សមាសភាពគណៈកម្មការត្រូវរួមបញ្ចូលអ្នកស្រាវជ្រាវ ឬអ្នកមានជំនាញដែលមានគុណវុឌ្ឍិ និង បទពិសោធសមស្របនឹងប្រធានបទ។

4. **រចនាសម្ព័ន្ធនិក្ខេបបទ**

- គ្រឹះស្ថានឧត្តមសិក្សាត្រូវរៀបចំគោលការណ៍ណែនាំស្តីពី ការរៀបចំនិក្ខេបបទស្របតាមការកំណត់របស់ក្រសួង អប់រំ យុវជន និងកីឡា
- គ្រឹះស្ថានឧត្តមសិក្សាត្រូវផ្ញើគោលការណ៍ណែនាំស្តីពីការរៀបចំនិក្ខេបបទនេះមកក្រសួង អប់រំ យុវជន និងកីឡា។

5. **គ្រូបង្រៀន គ្រូណែនាំ និងការដឹកនាំនិក្ខេបបទថ្នាក់បណ្ឌិត**

- សាស្ត្រាចារ្យ ឬគ្រូបង្រៀន៖ ត្រូវមានសញ្ញាបត្របណ្ឌិត មានបទពិសោធបង្រៀន និងមានស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវក្នុងទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រ
- សាស្ត្រាចារ្យ ឬគ្រូណែនាំនិក្ខេបបទ៖ ត្រូវមានសញ្ញាបត្របណ្ឌិត មានស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវក្នុង ទស្សនាវដ្តីស្រាវជ្រាវ និងមានបទពិសោធជាសាស្ត្រាចារ្យណែនាំ
- សហសាស្ត្រាចារ្យ ឬគ្រូណែនាំ៖ អាចមកពីស្ថាប័នខាងក្រៅ ជាអ្នកអនុវត្តផ្ទាល់ ដែលមានជំនាញ និងបទពិសោធស្របតាមប្រធានបទរបស់បេក្ខជន និងត្រូវមានសញ្ញាបត្របណ្ឌិត
- និស្សិតម្នាក់ៗត្រូវដឹកនាំដោយសាស្ត្រាចារ្យ ឬគ្រូណែនាំយ៉ាងតិចចំនួន២រូប (១រូបអាចជាអ្នកអនុវត្តផ្ទាល់មកពីខាងក្រៅដែលមានជំនាញ និងបទពិសោធស្របតាមប្រធានបទរបស់និស្សិត)។

តេឡេក្រាម ឯកសារមន្ត្រីរាជការ: - https://t.me/oa_channel

6. **ការពិនិត្យវឌ្ឍនភាពនៃការសិក្សា និងការស្រាវជ្រាវរបស់និស្សិត**

- គ្រឹះស្ថានឧត្តមសិក្សាត្រូវតម្រូវឱ្យនិស្សិតមានផែនការសិក្សា និងការស្រាវជ្រាវច្បាស់លាស់ ដោយត្រូវមានការណែនាំ និងយល់ព្រមពីសាស្ត្រាចារ្យ ឬគ្រូណែនាំគោល
- គ្រឹះស្ថានឧត្តមសិក្សាត្រូវមានយន្តការពិនិត្យវឌ្ឍនភាពនៃការសិក្សា និងការស្រាវជ្រាវរបស់និស្សិតប្រចាំត្រីមាស ឆមាស និងឆ្នាំ។ វឌ្ឍនភាពនេះត្រូវផ្តោតលើចំនួនក្រេឌីតសិក្សា ការប្រឡងតេស្តវាស់ស្ទង់សមត្ថភាព សំណើស្រាវជ្រាវ ការរីកចម្រើននៃការស្រាវជ្រាវ ការចូលរួម និងធ្វើបទបង្ហាញក្នុងសិក្ខាសាលាថ្នាក់ជាតិ ឬអន្តរជាតិ ការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវ ការសរសេរនិក្ខេបបទ និងការការពារនិក្ខេបបទបញ្ចប់ការសិក្សាជាដើម
- គ្រឹះស្ថានឧត្តមសិក្សាត្រូវរៀបចំប្រព័ន្ធត្រួតពិនិត្យតាមដានការសិក្សារបស់និស្សិត និងរៀបចំជារបាយការណ៍សង្ខេប ស្តីពីវឌ្ឍនភាព នៃការសិក្សាស្រាវជ្រាវរបស់និស្សិតរៀងរាល់ឆ្នាំ រួចផ្ញើមកក្រសួងអប់រំ យុវជន និងកីឡា។

7. **ការបោះពុម្ពផ្សាយ**

- គ្រឹះស្ថានឧត្តមសិក្សាត្រូវបញ្ជាក់ប្រភេទ ទស្សនាវដ្តីស្រាវជ្រាវសម្រាប់បោះពុម្ពផ្សាយឱ្យបានច្បាស់លាស់ដល់និស្សិត ជៀសវាងការបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីស្រាវជ្រាវដែលមិនមានគុណភាព
- គ្រឹះស្ថានឧត្តមសិក្សាត្រូវកំណត់ប្រភេទអត្ថបទស្រាវជ្រាវឱ្យបានច្បាស់លាស់ ដែលនិស្សិតត្រូវបោះពុម្ពសម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត
- គ្រឹះស្ថានឧត្តមសិក្សាដែលមានទស្សនាវដ្តីស្រាវជ្រាវសម្រាប់និស្សិតបោះពុម្ពផ្សាយ ត្រូវធានាថាទស្សនាវដ្តីស្រាវជ្រាវរបស់ខ្លួនមានគោលការណ៍ និងការអនុវត្តស្របតាមសៀវភៅណែនាំស្តីពីការបង្កើត ការគ្រប់គ្រង និងការអភិវឌ្ឍទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រ របស់ក្រសួងអប់រំ យុវជន និងកីឡា។

8. **ការការពារនិក្ខេបបទបញ្ចប់ការសិក្សា**

- គ្រឹះស្ថានឧត្តមសិក្សាត្រូវពង្រឹងការអនុវត្តលក្ខខណ្ឌសម្រាប់ការការពារនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតតាមប្រភេទនៃការបណ្តុះបណ្តាលនីមួយៗឱ្យស្របតាមបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- គ្រឹះស្ថានឧត្តមសិក្សាត្រូវសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា មុននឹងដំណើរការការពារនិក្ខេបបទបញ្ចប់ការសិក្សា។

9. **ក្រមសីលធម៌ស្រាវជ្រាវ និងការដាក់ពិន័យលើការលួចចម្លងស្នាដៃ**

- គ្រឹះស្ថានឧត្តមសិក្សាត្រូវមានគណៈកម្មការពិនិត្យ និងឯកភាពលើក្រមសីលធម៌នៃការស្រាវជ្រាវថ្នាក់បណ្ឌិត ដោយមានឧបករណ៍វាយតម្លៃក្រមសីលធម៌នៃការស្រាវជ្រាវសម្រាប់ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតច្បាស់លាស់

- គ្រឹះស្ថានឧត្តមសិក្សាត្រូវមានយន្តការពិនិត្យការលួចចម្លងស្នាដៃស្រាវជ្រាវ និងត្រូវមានឯកសារបញ្ជាក់ត្រឹមត្រូវថានិក្ខេបបទរបស់និស្សិត មិនមានការលួចចម្លងស្នាដៃពីអ្នកដទៃ
- គ្រឹះស្ថានឧត្តមសិក្សាត្រូវចែងឱ្យបានច្បាស់លាស់នៅក្នុងគោលការណ៍បណ្តុះបណ្តាលរបស់ខ្លួន ស្តីពីការដាក់ពិន័យដូចជា ការដកហូតសញ្ញាបត្របណ្ឌិត នៅពេលរកឃើញថាមានការលួចចម្លងស្នាដៃ ឬការប្រព្រឹត្តខុសក្រមសីលធម៌ស្រាវជ្រាវ។

ជាមួយគ្នានេះ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ថា រាល់សំណុំឯកសារ និងលិខិតស្នើសុំពាក់ព័ន្ធនឹងការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ត្រូវដាក់ចូលតាមរដ្ឋបាលរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

ទទួលបានសេចក្តីណែនាំនេះ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ ប្រធាននាយកដ្ឋានរដ្ឋបាល និងប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ និងគណៈគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ១៤រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមករា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**កន្លែងទទួល៖**
- អគ្គនាយកដ្ឋានឧត្តមសិក្សា
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី

**«ដើម្បីជូនជ្រាបជាព័ត៌មាន»**

- គ្រប់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន

**«ដើម្បីអនុវត្ត»**

- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ